سُورَةُ المُلْكِ

ស្វូរ៉ៅះត្ឋ៌ ៦៧

អាល់-មុលក៌

سُورَةُ المُلْكِ

ស្វ៊ូរ៉ោះតុ៌ ៦៧ អាល់-មុលក៏

"អាល់-មុលក៏" ប្រែថា "ព្រះអំណាចគ្រប់គ្រង" មាន ៣០ អាយ៉ាស្ុ ។

ស្វ៊ូរ៉ោះតុ៌ទី ៧៧ យោលតាមលេខរៀងដែលអល់ឡោះហ្ន៑ដាក់ចុះមក ។ អល់ឡោះហ្ន៑បានដាក់ ស្វ៊ូរ៉ោះតុ៌នេះចុះមកនៅឯម៉ាក់កាស្ុ ។

ប្រសិទ្ធភាព

وَ مِنْ (خَوَاصِّ الْقُرْآنِ): رُوِيَ عَنِ النَّبِيِّ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ) أَنَّهُ قَالَ: «مَنْ قَرَأَ هَذِهِ السُّورَةَ، وَ هِيَ الْمُنْجِيَةُ مِنْ عَذَابِ الْقَبْرِ، أُعْطِيَ مِنَ الْأَجْرِ كَمَنْ أَحْيَا لَيْلَةَ الْقَدْرِ، وَ مَنْ حَفِظَهَا كَانَتْ أَنِيسَهُ فِي قَبْرِهِ، تَدْفَعُ عَنْهُ كُلَّ نَازِلَةٍ تَهُمُّ بِهِ فِي قَبْرِهِ مِنَ الْعَذَابِ، وَ تَحْرُسُهُ إِلَى يَوْمِ بَعْثِهِ، وَ تَشْفَعُ لَهُ عِنْدَ رَبِّهَا وَ تُقَرِّبُهُ حَتَّى يَدْخُلَ الْجَنَّةَ آمِناً مِنْ وَحْشَتِهِ وَ وَحْدَتِهِ فِي قَبْرِهِ».** (خَوَاصِّ الْقُرْآنِ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٣٣ حَدِيث: ٩٩/ ١٠٩٠٥)

ដកស្រង់ពី[សាត្រា]ខ៏ហ៊ីស្ស៊ូ អាល់-ត្ងូរអានបានធ្វើសេចក្ដីរាយការណ៍តមកពីព្រះសាស្ដាﷺដែលមានព្រះវចនៈថា៖ "អ្នកណាសូត្រស្វ៊ូរ៉ោះតុ៌នេះ វានឹងជួយឲ្យរួចផុតពីទណ្ឌកម្មក្នុងផ្ទរ អ្នកនោះនឹងបានរង្ងាន់ហាក់ដូចជាមិនបានដេកក្នុងយប់បុព្ងបញ្ញត្ដិ (لَيْلَةَ الْقَدْرِ) ។ អ្នកណាទន្ទេញស្វ៊ូរ៉ោះតុ៌នេះចាំរត់មាត់ វានឹងទៅជាមិត្ដកំដររបស់អ្នកនោះក្នុងផ្ទរ វានឹងរុញច្រានរាល់ទណ្ឌកម្មដែលដាក់មកលើអ្នកនោះនៅក្នុងផ្ទរ វានឹងការពារអ្នកនោះលុះដល់ថ្ងៃរស់ឡើងវិញ វានឹងធ្វើអន្ដរាគមន៑ឲ្យអ្នកនោះពីព្រះម្ចាស់ﷻ វា នឹងនៅកែ្ឆ្ងរអ្នកនោះលុះត្រាតែអ្នកនោះបានចូលឋានសួគ៌ ផុតពីការណ៑ដែលគួរខ្លាចជាទីបំផុតនិងផុតពីអាការកណ្ដោចកណ្ដែងក្នុងផ្ទរ ។" (خَوَاصِّ الْقُرْآنِ)

***

وَ قَالَ رَسُولُ اللَّهِ (صَلَّى اللَّهُ عَلَيْهِ وَ آلِهِ): «مَنْ حَفِظَهَا كَانَتْ لَهُ أُنْساً فِي قَبْرِهِ، وَ تَشْفَعُ لَهُ عِنْدَ اللَّهِ يَوْمَ الْقِيَامَةِ حَتَّى يَدْخُلَ الْجَنَّةَ آمِناً، وَ مَنْ قَرَأَهَا وَ أَهْدَاهَا إِلَى إِخْوَانِهِ أَسْرَعَتْ إِلَيْهِمْ كَالْبَرْقِ الْخَاطِفِ، وَ خَفَّفَتْ عَنْهُمْ مَا هُمْ فِيهِ، وَ آنَسَتْهُمْ فِي قُبُورِهِمْ».** (البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٣٤ حَدِيث: ٩٩/ ١٠٩٠٦)

រ៉ាស្ងូលុលឡោះហ្ន៑ﷺមានព្រះវចនៈថា៖ "អ្នកណាចងចាំស្វ៊ូរ៉ោះតុ៌នេះស្ទាត់មាត់ វានឹងទៅជាមិត្ដកំដររបស់អ្នកនោះនៅក្នុងផ្ទរ វានឹងធ្វើអន្ដរាគមន៑ឲ្យអ្នកនោះពីអល់ឡោះហ្ន៑ﷻក្នុងថ្ងៃជំនុំជម្រះ ទាល់តែអ្នកនោះបានចូលក្នុងឋានសួគ៌ដោយសុវត្ដិភាព ។ អ្នកណាសូត្រស្វ៊ូរ៉ោះតុ៌នេះ ឲ្យវាជាអំណោយទៅបងប្អូនខ្លួន វានឹងស្ទុះទៅរកពួកគេដូចឆ្នូតពន្លឺ (ផ្លេកបន្ទោរ) ការពារខ្លួនពួកគេទល់នឹងគ្រប់ឧបសគ្គ វានឹងទៅជាមិត្ដកំដររបស់ពួកគេនៅក្នុងផ្ទរ ។" (تفسير البرهان ហ្ទ្ធាឌីស10906)

***

وَ قَالَ الصَّادِقُ (عَلَيْهِ السَّلَامُ): «مَنْ قَرَأَهَا عَلَى مَيِّتٍ خَفَّفَ اللَّهُ عَنْهُ مَا هُوَ فِيهِ، وَ إِذَا قُرِئَتْ وَ أُهْدِيَتْ إِلَى الْمَوْتَى أَسْرَعَتْ إِلَيْهِمْ

كَالْبَرْقِ الْخَاطِفِ بِإِذْنِ اللهِ تَعَالَى».** (خواص القرآن : ١١ «مخطوط». البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٣٤ حَدِيث: ١٠٩٠٧/٩٩)

អាល់-ស្ស៊ីឌ្ទิ្ធ ក្ដ صلوات الله عليه والسلام មានវចនៈថា៖ "អ្នកណាសូត្រស្វ៊ូរ៉ោះតុ៌នេះលើអ្នកស្លាប់ អល់ឡោះហ្ស៊ីដ ﷻ នឹងការពារសពនោះទល់នឹងគ្រប់ឧបសគ្គ ។ បើសូត្រស្វ៊ូរ៉ោះតុ៌នេះឧទ្ទិសឲ្យទៅអ្នកស្លាប់ វានឹងស្ទុះទៅរកអ្នកស្លាប់នោះដូចឆ្នូតពន្លឺ (ផ្លេកបន្ទោរ) អាស្រ័យការអនុញ្ញាតរបស់អល់ឡោះហ្ស៊ីដ ﷻ ។" (خواص القرآن: 11 «مخطوط»)

بِسۡمِ ٱللَّهِ ٱلرَّحۡمَٰنِ ٱلرَّحِيمِ

ដោយនូវព្រះនាមអល់ឡោះហ្ស៊ី ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

تَبَٰرَكَ ٱلَّذِى بِيَدِهِ ٱلۡمُلۡكُ وَهُوَ عَلَىٰ كُلِّ شَىۡءٍ قَدِيرٌ ١

១. ព្រះដែលក្តាប់ព្រះអំណាចគ្រប់គ្រង (ព្រះរាជាណាចក្រ) ក្នុងព្រះហត្ថព្រះអង្គប្រកបដោយព្រះភាគ (បុណ្យបារមី) ព្រះអង្គមានព្រះសព្វានុភាពលើសព្វសារពើ

អធិប្បាយអាយ៉ាតុ ១

[قَالَ:] وَ لَقَدْ مَرَّ أَمِيرُ الْمُؤْمِنِينَ عَلَيْهِ السَّلاَمُ عَلَى قَوْمٍ مِنْ أَخْلاَطِ الْمُسْلِمِينَ لَيْسَ فِيهِمْ مُهَاجِرِيٌّ وَ لاَ أَنْصَارِيٌّ، وَ هُمْ قُعُودٌ فِي بَعْضِ الْمَسَاجِدِ فِي أَوَّلِ يَوْمٍ مِنْ شَعْبَانَ، إِذَا هُمْ يَخُوضُونَ فِي أَمْرِ الْقَدَرِ وَ غَيْرِهِ مِمَّا اِخْتَلَفَ النَّاسُ فِيهِ، قَدِ اِرْتَفَعَتْ أَصْوَاتُهُمْ وَ اِشْتَدَّ فِيهِ مَحْكُهُمْ وَ جِدَالُهُمْ،

អ៊ីមុាំ អាល់-ហ្ស្ហាសាន់ صلوات الله عليه والسلام អាល់-អ្ហ្ម៉ាស់ការី صلوات الله عليه والسلام មានវចនៈថា៖ "មានព្រឹត្តិការណ៍មួយគឺ អាមីរុល-មុមីនីន صلوات الله عليه والسلام បានជួបមុស្លីមមួយក្រុម នៅក្នុងចំណោមពួកគេពុំមានអ្នកភៀសខ្លួន (مُهَاجِرِيٌّ) និងអ្នកជំនួយ (أَنْصَارِيٌّ) ទេ ។ ពួកគេបានអង្គុយជុំគ្នានៅក្នុងម៉ាស់ជិ្ដដូមួយនាថ្ងៃទីមួយខែស្ហ្ការ៉ាន់ ។ ពួកគេបានជជែកគ្នារឿងអាល់-ក្ដ្ដ (اَلْقَدَرِ ព្រេងវាសនានិងភាពជាម្ចាស់ខ្លួនឯង) និងរឿងដូចនេះឯទៀតដែលពួកគេមិនចុះសម្រុងគ្នា ។ ពួកគេដំឡើងសម្លេងក្នុងការជជែកវែកញ្ញែក ។

فَوَقَفَ عَلَيْهِمْ، فَسَلَّمَ، فَرَدُّوا عَلَيْهِ وَ أَوْسَعُوا وَ قَامُوا إِلَيْهِ يَسْأَلُونَهُ اَلْقُعُودَ إِلَيْهِمْ، فَلَمْ يَحْفِلْ بِهِمْ، ثُمَّ قَالَ لَهُمْ – وَ نَادَاهُمْ –: يَا مَعْشَرَ الْمُتَكَلِّمِينَ فِيمَا لاَ يَعْنِيهِمْ وَ لاَ يَرِدُ عَلَيْهِمْ، أَ لَمْ تَعْلَمُوا أَنَّ لِلَّهِ عِبَاداً قَدْ أَسْكَتَتْهُمْ خَشْيَتُهُ مِنْ غَيْرِ عِيٍّ وَ لاَ بَكَمٍ، وَ إِنَّهُمْ لَهُمُ اَلْفُصَحَاءُ اَلْعُقَلاَءُ اَلْأَلِبَّاءُ اَلْعَالِمُونَ بِاللَّهِ وَ أَيَّامِهِ. وَ لَكِنَّهُمْ إِذَا ذَكَرُوا عَظَمَةَ اَللَّهِ اِنْكَسَرَتْ أَلْسِنَتُهُمْ، وَ اِنْقَطَعَتْ أَفْئِدَتُهُمْ، وَ طَاشَتْ عُقُولُهُمْ، وَ هَامَتْ حُلُومُهُمْ، إِعْزَازاً لِلَّهِ وَ إِعْظَاماً وَ إِجْلاَلاً لَهُ.

ព្រះអង្គ صلوات الله عليه والسلام បានឈប់សម្រាកក្បែរពួកគេ ។ ព្រះអង្គ صلوات الله عليه والسلام បានសម្ដែងសេចក្ដីគួរសមចំពោះពួកគេ ពួកគេបានតបសេចក្ដីគួរសមព្រះអង្គ صلوات الله عليه والسلام វិញ ។ ពួកគេមួយចំនួនបានងើបឡើង ហើយបានវែកកន្លែងឲ្យព្រះអង្គ صلوات الله عليه والسلام អង្គុយជាមួយពួកគេ តែព្រះអង្គមិនអង្គុយជាមួយពួកគេទេ ។ បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام ហៅ

ពួកគេថា៖ "ក្រុមអ្នកនិយាយអើយ ដែលនិយាយគ្នាអំពីរឿងមួយដែលមិនជួយពួកគេបាននិងមិនផ្តល់ប្រយោជន៍ដល់ពួកគេសោះ ។ តើអស់លោកដឹងទេថាមានបាវបម្រើអល់ឡោះហ្ស៊ីដ្ជ ដែលមិននិយាយស្តីព្រោះតែខ្លាចព្រះអង្គ ﷻ ដែលមិនខ្វាក់និងមិនគ ។ ពួកគេមានប្រាជ្ញាទូលាយ មានចំណេះចេះដឹង ដែលអល់ឡោះហ្ស៊ីដ្ជចាត់ទុកថាជាអ្នកចេះដឹង ។ តែកាលណាព្រះអតិភាពអល់ឡោះហ្ស៊ីដ្ជលេចឮឡើង កាលនោះអណ្តាតពួកគេលែងកម្រើក បេះដូងពួកគេចាប់ផ្តើមលង់ ប្រាជ្ញាពួកគេសុញ ពួកគេលំអិនកាយចំពោះព្រះមហិទ្ធិឫទ្ធិព្រះអង្គ ﷻ ព្រះអតិភាព និងព្រះឧត្តមភាព ។

فَإِذَا أَفَاقُوا مِنْ ذَلِكَ اِسْتَبَقُوا إِلَى اَللَّهِ بِالْأَعْمَالِ اَلزَّاكِيَةِ، يَعُدُّونَ أَنْفُسَهُمْ مَعَ اَلظَّالِمِينَ وَ اَلْخَاطِئِينَ، وَ أَنَّهُمْ بِرَاءٌ مِنَ اَلْمُقَصِّرِينَ وَ اَلْمُفْرِطِينَ، إِلاَّ أَنَّهُمْ لاَ يَرْضَوْنَ لِلَّهِ بِالْقَلِيلِ وَ لاَ يَسْتَكْثِرُونَ لِلَّهِ اَلْكَثِيرَ، وَ لاَ يُدِلُّونَ عَلَيْهِ بِالْأَعْمَالِ فَهُمْ مَتَى مَا رَأَيْتَهُمْ مَهْمُومُونَ مُرَوَّعُونَ، خَائِفُونَ مُشْفِقُونَ، وَجِلُونَ.

កាលណាពួកគេនៅក្នុងសភាពនេះ កាលនោះពួកគេទៅរកអល់ឡោះហ្ស៊ីដ្ជដោយទង្វើសុក្រឹតបរិសុទ្ធ ពួកគេនៅតែចាត់ទុកខ្លួនឯងថាជាជនទុច្ចរិតនិងជាជនមានកំហុស ។ ពួកគេចាកឆ្ងាយពីបណ្តាអ្នកកាត់បន្ថយនិងអ្នកបំផ្លើស (اَلْمُقَصِّرِينَ وَ اَلْمُفْرِطِينَ) ពួកគេស្វាក់ស្ទើរចិត្តចំពោះអល់ឡោះហ្ស៊ីដ្ជមិនច្រើនទេ ហើយពួកគេមិនមានមោទនភាពចំពោះទង្វើរបស់ខ្លួនទេ ។ តែពេលណាគេមើលមកពួកគេ ពេលនោះគេឃើញពួកគេព្រួយបារម្ភ ភ័យរន្ធត់ ខ្លាចនិងកោត ។

فَأَيْنَ أَنْتُمْ مِنْهُمْ يَا مَعْشَرَ اَلْمُبْتَدِعِينَ أَ لَمْ تَعْلَمُوا أَنَّ أَعْلَمَ اَلنَّاسِ بِالْقَدَرِ أَسْكَتُهُمْ عَنْهُ وَ إِنْ أَجْهَلَ اَلنَّاسِ بِالْقَدَرِ أَنْطَقُهُمْ فِيهِ. (التفسير العسكرى عليه السلام : جُزْء ١ صَفْحَة ٦٣٥)

ឱក្រុមអ្នកកែប្រែអើយ តើអស់លោកជាគ្នារបស់ពួកគេទាំងនោះត្រង់ណាទៅ! តើអស់លោកដឹងទេថាទាក់ទងនឹងរឿងនេះ (اَلْقَدَرِ ព្រេងវាសនានិងភាពជាម្ចាស់ខ្លួនឯង) អ្នកដែលចេះដឹងគឺអ្នកដែលស្ងាត់ស្ងៀម ឯអ្នកខ្លៅគឺអ្នកដែលនិយាយស្តីច្រើនអំពីរឿងនេះ ?" (التفسير العسكرى عليه السلام 1: 635)

ٱلَّذِى خَلَقَ ٱلْمَوْتَ وَٱلْحَيَوٰةَ لِيَبْلُوَكُمْ أَيُّكُمْ أَحْسَنُ عَمَلًا ۚ وَهُوَ ٱلْعَزِيزُ ٱلْغَفُورُ ﴿٢﴾

២. ព្រះដែលបានបង្កើតការស្លាប់និងការរស់រានមានជីវិត ដើម្បីព្រះអង្គពិសោធពួកអ្នកឲ្យដឹងថាអ្នកណាខ្លះក្នុងចំណោមពួកអ្នកប្រព្រឹត្តល្អជាងគេ ។ ព្រះអង្គមានព្រះមហិទ្ធិឫទ្ធិ ព្រះអង្គទ្រង់អត់ឱន

អធិប្បាយអាយ៉ាស់ ២

مُحَمَّدُ بْنُ يَعْقُوبَ: بِإِسْنَادِهِ عَنْ فَضَالَةَ، عَنْ مُوسَى بْنِ بَكْرٍ، عَنْ زُرَارَةَ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ)، قَالَ: «الْحَيَاةُ وَ الْمَوْتُ خَلْقَانِ مِنْ خَلْقِ اللَّهِ، فَإِذَا جَاءَ الْمَوْتُ فَدَخَلَ فِي الْإِنْسَانِ، لَمْ يَدْخُلْ فِي شَيْءٍ إِلاَّ وَ قَدْ خَرَجَتْ مِنْهُ الْحَيَاةُ».** (الكافي : جُزْء ٣ صَفْحَة ٢٥٩ حَدِيث ٣٤ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٣٥ حَدِيث: ٩٩/ ١٠٩٠٩)

[...] អាប៊ូ យ៉ាកុ៉ាហ្ការ صلوات الله عليه والسلام មានវចន:ថា៖ "ជីវិតនិងការស្លាប់ជាវត្ថុដែលត្រូវបង្កើតពីរបស់អល់ឡោះហ្ស៊

ﷻ ។ ដូច្នេះ កាលណាការស្លាប់មកដល់ វានឹងចូលទៅខាងក្នុងមនុស្សជាតិ ។ ពេលវាចូលទៅក្នុងអ្វីមួយ ជីវិតត្រូវតែចាកចោលពីអ្វីនោះ ។" (الكافي 3: 259/ 34)

***

ابْنُ مَحْبُوبٍ عَنْ أَبِي جَعْفَرٍ الْأَحْوَلِ عَنْ سَلَّامِ بْنِ الْمُسْتَنِيرِ عَنْ أَبِي جَعْفَرٍ (عليه السلام) قَالَ إِنَّ اللَّهَ عَزَّ وَ جَلَّ خَلَقَ الْجَنَّةَ قَبْلَ أَنْ يَخْلُقَ النَّارَ وَ خَلَقَ الطَّاعَةَ قَبْلَ أَنْ يَخْلُقَ الْمَعْصِيَةَ وَ خَلَقَ الرَّحْمَةَ قَبْلَ الْغَضَبِ وَ خَلَقَ الْخَيْرَ قَبْلَ الشَّرِّ وَ خَلَقَ الْأَرْضَ قَبْلَ السَّمَاءِ وَ خَلَقَ الْحَيَاةَ قَبْلَ الْمَوْتِ وَ خَلَقَ الشَّمْسَ قَبْلَ الْقَمَرِ وَ خَلَقَ النُّورَ قَبْلَ الظُّلْمَةِ. (الكافي : جُزْء ٨ صَفْحَة ١٤٥)

[...] អាប៊ូ យ៉ាកុ៎ប្ហារ صلوات الله عليه والسلام មានវចន:ថា៖ "អល់ឡោះហ្ស៊ីﷻ បានបង្កើតឋានសួគ៌មុនព្រះអង្គﷻ បង្កើតនរក ។ ព្រះអង្គﷻ បានបង្កើតការស្តាប់បង្គាប់មុនព្រះអង្គﷻ បានបង្កើតការប្រទូសប្រឆាំង ។ ព្រះអង្គﷻ បានបង្កើតមេត្តាធម៌មុនទោស: ។ ព្រះអង្គﷻ បានបង្កើតសេចក្តីល្អមុនសេចក្តីអាក្រក់ ។ ព្រះអង្គﷻ បានបង្កើតដីមុនមេឃ ។ ព្រះអង្គﷻ បានបង្កើតជីវិតមុនការស្លាប់ ។ ព្រះអង្គﷻ បានបង្កើតដួងអាទិត្យមុនដួងខែ ។ ព្រះអង្គﷻ បានបង្កើតរស្មីមុនភាពងងឹត ។" (الكافي 8: 145/ 116)

***

فِي اِعْتِقَادَاتِ اَلْإِمَامِيَّةِ لِلصَّدُوقِ (ره) قِيلَ لِعَلِيِّ بْنِ اَلْحُسَيْنِ عَلَيْهِمَا اَلسَّلاَمُ: مَا اَلْمَوْتُ؟ قَالَ: اَلْمَوْتُ لِلْمُؤْمِنِ كَنَزْعِ ثِيَابٍ وَسِخَةٍ قَمِلَةٍ وَ فَكِّ قُيُودٍ وَ أَغْلاَلٍ ثَقِيلَةٍ، وَ اَلِاسْتِبْدَالِ بِأَفْخَرِ اَلثِّيَابِ وَ أَطْيَبِهَا رَوَائِحَ. وَ أَوْطَإِ اَلْمَرَاكِبِ وَ آنَسِ اَلْمَنَازِلِ، وَ لِلْكَافِرِ كَخَلْعِ ثِيَابٍ فَاخِرَةٍ وَ اَلنَّقْلِ عَنْ مَنَازِلَ أَنِيسَةٍ وَ اَلِاسْتِبْدَالِ بِأَوْسَخِ اَلثِّيَابِ وَ أَخْشَنِهَا، وَ أَوْحَشِ اَلْمَنَازِلِ وَ أَعْظَمِ اَلْعَذَابِ. (تفسير نور الثقلين : جُزْء ٥ صَفْحَة ٣٨٠)

នៅក្នុង[សាត្រា] អ៊ីម៉ូ៉ាទីក្ខ៊ីដ្ឋាត់ អាល់-អ៊ីម៉ាមីយ៉ាសុ៎ របស់ អាល់-ស្ស៊ីឌ្ធ ក្ខ គេបានសួរ អ៊ីម៉ាលី صلوات الله عليه والسلام ប៊ីន អាល់-ហ្ស៊ូសៃន៍ صلوات الله عليه والسلام ថា៖ "អ្វីទៅការស្លាប់ ?" ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "សម្រាប់អ្នកមានសទ្ធាជ្រះថ្លា ការស្លាប់ប្រៀបបាននឹងការយកវត្ថុកខ្វក់និងចៃចេញពីសំលៀកបំពាក់ និងការលើកចោលច្រវ៉ាក់ធ្ងន់និងពិបាកស៊ូទ្រាំ ដើម្បីប្តូរផ្លាស់ដោយសំលៀកបំពាក់អស្ចារ្យនិងគ្រឿងក្រអូបប្រសើរបំផុត និងដោយជំនិះងាយស្រួលបំផុតនិងគេហដ្ឋានជាទីស្រឡាញ់ ។ សម្រាប់អ្នកបដិសេធសទ្ធា វាប្រៀបបាននឹងការដោះសំលៀកបំពាក់ប្រណិត [ប្រៀបបាននឹងការ]ជម្លៀសពីគេហដ្ឋានជាទីស្រឡាញ់ទៅប្តូរនឹងសំលៀកបំពាក់កខ្វក់គគ្រាតជាងនោះ [ប្តូរនឹង]ផ្ទះអាក្រក់និងទណ្ឌកម្មធំ ។" (تفسير نور الثقلين វគ្គ ៦៧ ហ្ស៊ីឌ្ធ ១០)

***

وَ عَنْهُ: عَنْ عَلِيِّ بْنِ إِبْرَاهِيمَ، عَنْ أَبِيهِ، عَنِ الْقَاسِمِ بْنِ مُحَمَّدٍ، عَنِ الْمِنْقَرِيِّ، عَنْ سُفْيَانَ بْنِ عُيَيْنَةَ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، فِي قَوْلِ اللَّهِ عَزَّ وَ جَلَّ: ''لِيَبْلُوَكُمْ أَيُّكُمْ أَحْسَنُ عَمَلاً''، قَالَ: «لَيْسَ يَعْنِي أَكْثَرَكُمْ عَمَلاً، وَ لَكِنْ أَصْوَبَكُمْ عَمَلاً، وَ إِنَّمَا الْإِصَابَةُ خَشْيَةُ اللَّهِ وَ النِّيَّةُ الصَّادِقَةُ وَ الْحَسَنَةُ

[...] អាប៊ូ អ្ហ៊ាប់ឌ្ធុលឡោះហ្ស៊ី صلوات الله عليه والسلام មានវចន:អំពីព្រះបន្ទូលអល់ឡោះហ្ស៊ីﷻ *[៦៧:២] ដើម្បីព្រះអង្គពិសោធពួកអ្នកឲ្យដឹងថាអ្នកណាខ្លះក្នុងចំណោមពួកអ្នកប្រព្រឹត្តល្អជាងគេ* ថា៖ "មិនមានន័យថាអ្នកណាម្នាក់ក្នុងចំណោមអស់លោកមានទង្វើច្រើនលើសគេនោះទេ ផ្ទុយទៅវិញ គឺមានទង្វើត្រឹមត្រូវច្រើនជាងគេ ។ ត្រឹមត្រូវគឺការដាក់ខ្លួនចំពោះអល់ឡោះហ្ស៊ីﷻ បំណងត្រឹមត្រូវនិងសេចក្តីល្អ ។"

- ثُمَّ قَالَ- اَلْإِبْقَاءُ عَلَى الْعَمَلِ حَتَّى يَخْلُصَ أَشَدُّ مِنَ الْعَمَلِ، أَلاَ وَ الْعَمَلُ الْخَالِصُ: اَلَّذِي لاَ تُرِيدُ أَنْ يَحْمَدَكَ عَلَيْهِ أَحَدٌ إِلاَّ اللهُ عَزَّ وَ جَلَّ، وَ النِّيَّةُ أَفْضَلُ مِنَ الْعَمَلِ، أَلاَ وَ إِنَّ النِّيَّةَ هِيَ الْعَمَلُ- ثُمَّ تَلاَ قَوْلَهُ عَزَّ وَ جَلَّ- ''قُلْ كُلٌّ يَعْمَلُ عَلىٰ شَاكِلَتِهِ'' يَعْنِي عَلَى نِيَّتِهِ».**
(الكافي : جُزْء ٢ صَفْحَة ١٣ حَدِيث ٤ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٣٥ حَدِيث: ٩٩/ ١٠٩١٠)

បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ "បន្ត ទង្វើលុះត្រាបានចប់ជាស្ថាពរពិបាកលើសធ្វើទង្វើទៅទៀត ។ ទង្វើដែលស្មោះគឺទង្វើដែលលោកមិនចង់ឲ្យគេសរសើរទេ លើកលែងតែចង់ឲ្យអល់ឡោះ ﷻ មួយគត់សរសើរប៉ុណ្ណោះ ។ បំណងធំជាងទង្វើទៅទៀត ។ ការពិត បំណងគឺទង្វើ" បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام សូត្រព្រះបន្ទូលអល់ឡោះ ﷻ *[១៧:៨៤] ចូរអ្នកថ្លែងថា៖ "ម្នាក់ៗរមែងប្រព្រឹត្តតាមអជ្ឈត្តសន្ទានរៀងខ្លួន* មានន័យថាតាមបំណងរបស់ខ្លួន ។" (الكافي 2: 13/ 4)

ٱلَّذِى خَلَقَ سَبْعَ سَمَٰوَٰتٍ طِبَاقًا ۖ مَّا تَرَىٰ فِى خَلْقِ ٱلرَّحْمَٰنِ مِن تَفَٰوُتٍ ۖ فَٱرْجِعِ ٱلْبَصَرَ هَلْ تَرَىٰ مِن فُطُورٍ ﴿٣﴾

៣. ព្រះអង្គបានបង្កើតមេឃទាំងប្រាំពីរជាស្រទាប់ ។ អ្នកមិនឃើញមាននូវភាពមិនស្របគ្នា (មិនត្រូវគ្នា) ឡើយនៅក្នុងការបង្កបង្កើតរបស់ព្រះដ៏មានព្រះមេត្តាធម៌ ។ ចូរអ្នកសង្កេតមើលវិញ តើអ្នកឃើញមានខ្វោះទេ ?

ثُمَّ ٱرْجِعِ ٱلْبَصَرَ كَرَّتَيْنِ يَنقَلِبْ إِلَيْكَ ٱلْبَصَرُ خَاسِئًا وَهُوَ حَسِيرٌ ﴿٤﴾

៤. ចូរអ្នកសង្កេតមើលម្តងទៀត ។ ខ្សែចក្ខុរបស់អ្នកនឹងត្រឡប់មករកអ្នកវិញដោយអន់ថយនិងនឿយហត់ ។

وَلَقَدْ زَيَّنَّا ٱلسَّمَآءَ ٱلدُّنْيَا بِمَصَٰبِيحَ وَجَعَلْنَٰهَا رُجُومًا لِّلشَّيَٰطِينِ ۖ وَأَعْتَدْنَا لَهُمْ عَذَابَ ٱلسَّعِيرِ ﴿٥﴾

៥. ពិតណាស់ យើងបានតុបតែងមេឃលោកិយដោយប្រទីប ។ យើងបានធ្វើឲ្យប្រទីបទាំងនោះទៅជាគ្រឿងចោលពួកស្ដ្ងតូន យើងបានត្រៀមទុកសម្រាប់ពួកវានូវទណ្ឌកម្មភ្លើងនរក ។

وَلِلَّذِينَ كَفَرُوا۟ بِرَبِّهِمْ عَذَابُ جَهَنَّمَ ۖ وَبِئْسَ ٱلْمَصِيرُ ﴿٦﴾

៦. ទណ្ឌកម្មនរកសម្រាប់ជនណាដែលមិនមានសទ្ធាចំពោះព្រះម្ចាស់ខ្លួន (ដែលប្រទូសប្រឆាំងព្រះបញ្ជាព្រះអង្គយ៉ាងមាន:) វាជាទីដៅអប្រិយ ។

إِذَآ أُلْقُوا۟ فِيهَا سَمِعُوا۟ لَهَا شَهِيقًا وَهِىَ تَفُورُ ﴿٧﴾

៧. ពេលពួកគេនឹងត្រូវច្រានចូលទៅក្នុងនោះ ពួកគេនឹងឮវាដកដង្ហើម វានឹងពុះគគ្រាក់ ។

تَكَادُ تَمَيَّزُ مِنَ ٱلْغَيْظِ ۖ كُلَّمَآ أُلْقِىَ فِيهَا فَوْجٌ سَأَلَهُمْ خَزَنَتُهَآ أَلَمْ يَأْتِكُمْ نَذِيرٌ ﴿٨﴾

៨. វាស្ទើរតែផ្ទុះដោយកំហឹង (ភ្លើងនរក) ។ រាល់ពេលដែលមួយក្រុម[នៃពួកមានទោស]ត្រូវទម្លាក់ទៅក្នុងនោះ បណ្ដាឆ្មាំវាសួរពួកគេថា៖ "តើមានអ្នកដាស់តឿន [ក្នុងព្រះនាមអល់ឡោះ ﷻ] បានមករកពួកអ្នកទេ ?"

قَالُواْ بَلَىٰ قَدۡ جَآءَنَا نَذِيرٞ فَكَذَّبۡنَا وَقُلۡنَا مَا نَزَّلَ ٱللَّهُ مِن شَيۡءٍ إِنۡ أَنتُمۡ إِلَّا فِي ضَلَٰلٖ كَبِيرٖ ٩

៩. ពួកគេនឹងថា៖ "មាន ។ អ្នកដាស់តឿនម្នាក់បានមករកយើងមែនតែយើងបានជំទាស់ ។ យើងបានថា៖ "អល់ឡោះហ្ស៊ាពុំបានដាក់អ្វីចុះមកទាល់តែសោះ ។ អស់លោក [អ្នកដាស់តឿន] នៅក្នុងកំហុសធំ !""

អធិប្បាយអាយ៉ាស់ ៣-៩

* وَ فِي رِوَايَةِ أَبِي اَلْجَارُودِ عَنْ أَبِي جَعْفَرٍ عَلَيْهِ اَلسَّلاَمُ: فِي قَوْلِهِ: ''سَبْعَ سَمَاوَاتٍ طِبَاقاً'' يَقُولُ: بَعْضُهَا فَوْقَ بَعْضٍ. (تفسير نور الثقلين : جُزْء ٥ صَفْحَة ٤٢٥)

* អាប៊ូ អាល់-ជ្ជ៉ារូដ្ឋបានរាយការណ៍ថា អាប៊ូ ជ្ជ៉ាហ្ហារ صلوات الله عليه والسلام មានវចន:អំពីព្រះបន្ទូលអល់ឡោះហ្ស៊ា عز وجل *[៧១:១៥] មេឃទាំងប្រាំពីរជាស្រទាប់* ថា៖ "មួយពីលើមួយទៀត ។" (تفسير نور الثقلين 5: 425)

***

عَلِيُّ بْنُ إِبْرَاهِيمَ، قَالَ: حَدَّثَنِي أَبِي، عَنِ الْحُسَيْنِ بْنِ خَالِدٍ، عَنْ أَبِي الْحَسَنِ الرِّضَا (عَلَيْهِ السَّلاَمُ)، قَالَ: قُلْتُ لَهُ: أَخْبِرْنِي عَنْ قَوْلِ اللَّهِ عَزَّ وَ جَلَّ: ''وَ السَّمَاءِ ذَاتِ الْحُبُكِ''. فَقَالَ: هِيَ «مَحْبُوكَةٌ إِلَى الْأَرْضِ»، وَ شَبَّكَ بَيْنَ أَصَابِعِهِ. فَقُلْتُ: كَيْفَ تَكُونُ مَحْبُوكَةً إِلَى الْأَرْضِ، وَ اللَّهُ يَقُولُ: ''رَفَعَ السَّمَاوَاتِ بِغَيْرِ عَمَدٍ تَرَوْنَهَا''؟ فَقَالَ: «سُبْحَانَ اللَّهِ! أَ لَيْسَ اللَّهُ يَقُولُ: ''بِغَيْرِ عَمَدٍ تَرَوْنَهَا''؟». قُلْتُ: بَلَى. فَقَالَ: «ثَمَّ عَمَدٌ وَ لَكِنْ لاَ تَرَوْنَهَا».

[...] ខ្ញុំបានសួរ អាប៊ូ អាល់-ហ្ហាសាន់ អាល់-រីដ្ធ صلوات الله عليه والسلام ថា៖ "សូមព្រះអង្គ صلوات الله عليه والسلام ប្រាប់ទូលបង្គំអំពីព្រះបន្ទូលអល់ឡោះហ្ស៊ា عز وجل *[៥១:៧] [អញ្ជសូមស្ប្ជ]ចំពោះមេឃដែលពេញដោយផ្លូវ* ។ ព្រះអង្គ صلوات الله عليه والسلام មានវចន: ថា៖ "វាភ្ជាប់មកឯផែនដី ។" ព្រះអង្គ صلوات الله عليه والسلام បានជៀតម្រាមដៃព្រះអង្គ صلوات الله عليه والسلام ឲ្យជិតគ្នា ។ ខ្ញុំបានទូលថា៖ "តើវាភ្ជាប់មកលើផែនដូចម្តេចទៅ អល់ឡោះហ្ស៊ា عز وجل មានព្រះបន្ទូលថា *[១៣:២] អល់ឡោះហ្ស៊ាជាអ្នកលើកមេឃទាំងឡាយឡើងដោយឥតមានសសរដែលពួកអ្នកអាចមើលឃើញបាន* ?" ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "សូមថ្វាយសេចក្ដីរុងរឿងចំពោះអល់ឡោះហ្ស៊ា عز وجل ! តើអល់ឡោះហ្ស៊ា عز وجل មិនមានព្រះបន្ទូលទេថា *ឥតសសរដែលពួកអ្នកអាចមើលឃើញបាន* ?" ខ្ញុំបានថា៖ "មែនហើយ ។" ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "វាមានសសរ តែអស់លោកមើលសសរទាំងនោះមិនឃើញទេ ។"

قُلْتُ: كَيْفَ ذَلِكَ، جَعَلَنِيَ اللَّهُ فِدَاكَ؟ قَالَ: فَبَسَطَ كَفَّهُ الْيُسْرَى، ثُمَّ وَضَعَ الْيُمْنَى عَلَيْهَا، فَقَالَ: «هَذِهِ أَرْضُ الدُّنْيَا، وَ السَّمَاءُ الدُّنْيَا فَوْقَهَا قُبَّةٌ، وَ الْأَرْضُ الثَّانِيَةُ فَوْقَ السَّمَاءِ الدُّنْيَا، وَ السَّمَاءُ الثَّانِيَةُ فَوْقَهَا قُبَّةٌ، وَ الْأَرْضُ الثَّالِثَةُ فَوْقَ السَّمَاءِ الثَّانِيَةِ، وَ السَّمَاءُ الثَّالِثَةُ فَوْقَهَا قُبَّةٌ، وَ الْأَرْضُ الرَّابِعَةُ فَوْقَ السَّمَاءِ الثَّالِثَةِ، وَ السَّمَاءُ الرَّابِعَةُ فَوْقَهَا قُبَّةٌ، وَ الْأَرْضُ الْخَامِسَةُ فَوْقَ السَّمَاءِ الرَّابِعَةِ، وَ السَّمَاءُ الْخَامِسَةُ فَوْقَهَا قُبَّةٌ، وَ الْأَرْضُ السَّادِسَةُ، فَوْقَ السَّمَاءِ الْخَامِسَةِ، وَ السَّمَاءُ السَّادِسَةُ فَوْقَهَا قُبَّةٌ، وَ الْأَرْضُ السَّابِعَةُ فَوْقَ السَّمَاءِ السَّادِسَةِ، وَ السَّمَاءُ السَّابِعَةُ فَوْقَهَا قُبَّةٌ،

ខ្ញុំបានទូលថា៖ "សូមឲ្យទូលបង្គំបានធ្វើពលីកម្មដើម្បីព្រះអង្គ صلوات الله عليه والسلام តើវាយ៉ាងម៉េចទៅ ?" ព្រះអង្គ صلوات الله عليه والسلام

ត្រដាងដៃឆ្វេងព្រះអង្គ صلوات الله عليه والسلام ដាក់ដៃស្តាំព្រះអង្គ صلوات الله عليه والسلام លើដៃឆ្វេង ហើយព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "នេះគឺដីលោកនេះនិងមេយលោកនេះ ឯខាងលើគឺដោម ។ លោកទីពីរនៅពីលើមេយលោកនេះ ហើយមានដោមមួយនៅពីលើមេយទីពីរ ។ ដីទីបីនៅពីលើមេយទីពីរ ហើយមានដោមមួយនៅពីលើមេយទីបី ។ ដីទីបួននៅពីលើមេយទីបី មានដោមមួយនៅពីលើមេយទីបួន ។ ដីទីប្រាំនៅពីលើមេយទីបួន មានដោមមួយនៅពីលើមេយទីប្រាំ ។ ដីទីប្រាំមួយនៅពីលើមេយទីប្រាំ មានដោមមួយនៅពីលើមេយទីប្រាំមួយ ។ ដីទីប្រាំពីរនៅពីលើមេយទីប្រាំមួយ មានដោមមួយនៅពីលើមេយទីប្រាំពីរ ។

وَ عَرْشُ الرَّحْمَنِ تَبَارَكَ وَ تَعَالَى فَوْقَ السَّمَاءِ السَّابِعَةِ، وَ هُوَ قَوْلُ اللهِ عَزَّ وَ جَلَّ: ''اَلَّذِي خَلَقَ سَبْعَ سَمَاوَاتٍ'' طِبَاقاً ''وَ مِنَ الْأَرْضِ مِثْلَهُنَّ يَتَنَزَّلُ الْأَمْرُ بَيْنَهُنَّ'' فَأَمَّا صَاحِبُ الْأَمْرِ فَرَسُولُ اللهِ (صَلَّى اللهُ عَلَيْهِ وَ آلِهِ)، وَ الْوَصِيُّ بَعْدَ رَسُولِ اللهِ (صَلَّى اللهُ عَلَيْهِ وَ آلِهِ) قَائِمٌ عَلَى وَجْهِ الْأَرْضِ، فَإِنَّمَا يَتَنَزَّلُ الْأَمْرُ إِلَيْهِ مِنْ فَوْقِ السَّمَاءِ مِنْ بَيْنِ السَّمَاوَاتِ وَ الْأَرَضِينَ». قُلْتُ: فَمَا تَحْتَنَا إِلاَّ أَرْضٌ وَاحِدَةٌ؟ فَقَالَ: «مَا تَحْتَنَا إِلاَّ أَرْضٌ وَاحِدَةٌ، وَ إِنَّ السِّتَّ لَهُنَّ فَوْقَنَا».** (تفسير القمى : جُزْء ٢ صَفْحَة ٣٢٨)

ព្រះរាជបល្ល័ង្ករបស់ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានសិរីសួស្តី នៅពីលើមេយទីប្រាំពីរ នេះគឺព្រះបន្ទូលអល់ឡោះហ្ស៊ីវ៉ាជ *[៦៥:១២] អល់ឡោះហ្ស៊ីវ៉ាជ*ាព្រះអ្នកបង្កើតមេយទាំងប្រាំពីរ ជាស្រទាប់ៗ (ជាជាន់ៗ) *និងផែនដីស្រដៀងមេយនោះដែរ ។ ព្រះបញ្ជាចុះមកឯពួកវាទាំងអស់នោះ ។* រីឯព្រះម្ចាស់នៃព្រះបញ្ជាគឺរ៉ាស៊ូលុលឡោះហ្ស៊ីវ៉ាជ صلى الله عليه وآله وسلم និងព្រះឧត្តរាធិការី عليهم السلام (គឺអ្នកស្នង) បន្ទាប់ពីរ៉ាស៊ូលុលឡោះហ្ស៊ីវ៉ាជ صلى الله عليه وآله وسلم ឋិតនៅលើផ្ទៃផែនដី ។ ព្រះរាជបញ្ជាចុះមកលើព្រះអង្គ صلى الله عليه وآله وسلم ពីលើមេយ មកពីលើមេយទាំងប្រាំពីរនិងផែនដីទាំងប្រាំពីរ ។" ខ្ញុំបានទូលថា៖ "ពុំមានអ្វីទេនៅពីក្រោមយើង ក្រៅពីផែនដីមួយ ?" ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "មិនមានអ្វីទេនៅពីក្រោមយើង ក្រៅពីផែនដីមួយ និងប្រាំមួយទៀតនៅពីលើយើង ។"

(تفسير القمّي 2: 328)13:2-3, 51:7

***

* ابْنُ بَابَوَيْهِ، قَالَ: حَدَّثَنَا عَلِيُّ بْنُ أَحْمَدَ بْنِ عَبْدِ اللهِ بْنِ أَحْمَدَ بْنِ أَبِي عَبْدِ اللهِ الْبَرْقِيُّ، قَالَ: حَدَّثَنِي أَبِي، عَنْ جَدِّهِ أَحْمَدَ بْنِ أَبِي عَبْدِ اللهِ، عَنْ أَحْمَدَ بْنِ مُحَمَّدِ بْنِ أَبِي نَصْرٍ الْبَزَنْطِيِّ، عَنْ أَبَانِ بْنِ عُثْمَانَ، عَنْ أَبِي عَبْدِ اللهِ الصَّادِقِ (عَلَيْهِ السَّلاَمُ) قَالَ: «كَانَ إِبْلِيسُ (لَعَنَهُ اللهُ) يَخْتَرِقُ السَّمَاوَاتِ السَّبْعَ، فَلَمَّا وُلِدَ عِيسَى (عَلَيْهِ السَّلاَمُ)، حُجِبَ عَنْ ثَلاَثِ سَمَاوَاتٍ، وَ كَانَ يَخْتَرِقُ أَرْبَعَ سَمَاوَاتٍ، فَلَمَّا وُلِدَ رَسُولُ اللهِ (صَلَّى اللهُ عَلَيْهِ وَ آلِهِ)، حُجِبَ عَنِ السَّبْعِ كُلِّهَا، وَ رُمِيَتِ الشَّيَاطِينُ بِالنُّجُومِ، ** (الأمالى (للصدوق) : صَفْحَة ٢٣٥ حَدِيث ١ ، البرهان في تفسير القرآن الجُزْء : ٣ صَفْحَة : ٣٣٤)

* អ៊ីបនូ បាបាវ៉ៃហ្ស៊ីមានប្រសាសន៍ថា អ៊ូលី ប៊ិន អាស្ម៉ាដ្ដ ប៊ិន អ៊ូប៉ាឌ្ឌុលឡោះហ្ស៊ី ប៊ិន អាស្ម៉ាដ្ដ ប៊ិន អាប៊ូ អ៊ូប៉ាឌ្ឌុលឡោះហ្ស៊ី អាល់-បារគ្ពីបានរាយការណ៍ប្រាប់យើងថាឪពុកខ្ញុំបាននិយាយប្រាប់ខ្ញុំតមកពីជីតាលោកឈ្មោះអាស្ម៉ាដ្ដ ប៊ិន អាប៊ូ អ៊ូប៉ាឌ្ឌុលឡោះហ្ស៊ី តមកពី អាស្ម៉ាដ្ដ ប៊ិន មូហ្ហាំម៉ាដ្ដ ប៊ិន អាប៊ូ ណាស្ស៊ែ អាល់-បាស្ហាន់ទ្ធី តមកពី អាបាន ប៊ិន អ៊ុស្ម៉ាន តមកពី អាប៊ូ អ៊ូប៉ាឌ្ឌុលឡោះហ្ស៊ី អាល់-ស្ស៊ីឌ្ធិក្ធ صلوات الله عليه والسلام ដែលមានវចន:ថា៖ "អ៊ីប្លីស لعن الله ធ្លាប់តែចូលទៅក្នុងមេយទីប្រាំពីរ ។ កាលព្រះសាស្តាអ៊ីសា عليه السلام ត្រូវចាត់បញ្ជូនមក[ឯផែនដី] គេបានរារាំងវា لعن الله នៅឯមេយទីបី វា لعن الله ធ្លាប់តែចូលទៅក្នុងមេយទីបួន ។ កាលរ៉ាស៊ូលុលឡោះហ្ស៊ី صلى الله عليه وآله وسلم មកដល់ គេបានរារាំងវា لعن الله មិនចូលទៅក្នុងមេយទាំងប្រាំពីរ ពួកបិសាចត្រូវចោលដោយធូមកេតុ (ផ្កាយដុះកន្ទុយ) ។" (الأمالى (للصدوق): 235 / 1) 52:38

***

ابْنُ بَابَوَيْهِ، قَالَ: حَدَّثَنَا عَلِيُّ بْنُ أَحْمَدَ (رَحِمَهُ اللَّهُ)، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ أَبِي عَبْدِ اللَّهِ الْكُوفِيُّ، عَنْ مُوسَى بْنِ عِمْرَانَ، عَنْ عَمِّهِ الْحُسَيْنِ بْنِ يَزِيدَ، عَنْ عَلِيِّ بْنِ أَبِي حَمْزَةَ، عَنْ أَبِي بَصِيرٍ، عَنْ أَبِي عَبْدِ اللَّهِ (عَلَيْهِ السَّلاَمُ)، أَنَّهُ سَأَلَهُ رَجُلٌ فَقَالَ: لِأَيِّ شَيْءٍ بَعَثَ اللَّهُ الْأَنْبِيَاءَ وَ الرُّسُلَ إِلَى النَّاسِ؟ فَقَالَ: «لِئَلاَّ يَكُونَ لِلنَّاسِ عَلَى اللَّهِ حُجَّةٌ بَعْدَ الرُّسُلِ، وَ لِئَلاَّ يَقُولُوا: مَا جَاءَنَا مِنْ بَشِيرٍ وَ لاَ نَذِيرٍ، وَ لِتَكُونَ حُجَّةُ اللَّهِ عَلَيْهِمْ، أَ لاَ تَسْمَعُ قَوْلَ اللَّهِ عَزَّ وَ جَلَّ، يَقُولُ حِكَايَةً عَنْ خَزَنَةِ جَهَنَّمَ وَ احْتِجَاجِهِمْ عَلَى أَهْلِ النَّارِ بِالْأَنْبِيَاءِ وَ الرُّسُلِ: ''أَ لَمْ يَأْتِكُمْ نَذِيرٌ * قَالُوا بَلىٰ قَدْ جَاءَنَا نَذِيرٌ فَكَذَّبْنَا وَ قُلْنَا مَا نَزَّلَ اللهُ مِنْ شَيْءٍ إِنْ أَنْتُمْ إِلاَّ فِي ضَلاَلٍ كَبِيرٍ''؟».** (علل الشرائع : صَفْحَة ١٢٠ حَدِيث ٤ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤٠ حَدِيث: ٩٩/ ١٠٩١٣)

បុរសម្នាក់បានសួរអាប៊ូ អ្ហាប់ឌ្ឍុលឡោះហ្ស៊ាមានសន្តិភាពនិងសិរីល្អ ថា៖ "ហេតុអ្វីអល់ឡោះហ្ស៊ាមានកិត្តិយសបានចាត់បញ្ជូនបណ្តាព្រះសាស្តានិងសាសន:ទូតមានសន្តិភាពនិងសិរីល្អមករកមនុស្ស ?" ព្រះអង្គមានសន្តិភាពនិងសិរីល្អមានវចន:ថា៖ "ក្រែងតែមនុស្សឆ្លើយដោះសាដាក់អល់ឡោះហ្ស៊ាមានកិត្តិយសពេលអត់ពីព្រះសាសន:ទូតមានសន្តិភាពនិងសិរីល្អ ក្រែងលោពួកគេថា៖ "មិនដែលមានអ្នកឲ្យដំណឹងល្អឬអ្នកព្រមានណាម្នាក់មករកយើងទេ" និងដើម្បីឲ្យព្រះអង្គទាំងអស់មានសន្តិភាពនិងសិរីល្អ (ព្រះសាស្តានិងព្រះសាសន:ទូត) ទៅជាពាក្យសំអាងរបស់អល់ឡោះហ្ស៊ាមានកិត្តិយសទល់នឹងពួកគេ ។ លោកមិនដែលបានឮទេ ព្រះបន្ទូលអល់ឡោះហ្ស៊ាមានកិត្តិយសដែលចែងអំពីបណ្តាឆ្នាំនរកនិងពាក្យសំអាងរបស់ពួកគេដាក់ពួកនរក តាមរយ: ព្រះសាស្តានិងព្រះសាសន:ទូតទាំងឡាយមានសន្តិភាពនិងសិរីល្អ ? *[៦៧:៨] រាល់ពេលដែលមួយក្រុមត្រូវទម្លាក់ទៅក្នុងនោះ បណ្តាឆ្នាំវាសួរពួកគេថា៖ "តើមានអ្នកដាស់តឿនបានមករកពួកអ្នកទេ ?" [៦៧:៩] ពួកគេនឹងថា៖ "មាន ។ អ្នកដាស់តឿនម្នាក់បានមករកយើងមែនតែយើងបានជំទាស់ ។ យើងបានថា៖ "អល់ឡោះហ្ស៊ាមានកិត្តិយសពុំបានដាក់អ្វីចុះមកទាល់តែសោះ ។ អស់លោកនៅក្នុងកំហុសធំ !""* ?" (علل الشرائع: 4/ 120)

***

* فِي كِتَابِ اَلْإِحْتِجَاجِ لِلطَّبْرِسِيِّ (ره) بِإِسْنَادِهِ إِلَى اَلْإِمَامِ مُحَمَّدِ بْنِ عَلِيٍّ اَلْبَاقِرِ عَلَيْهِمَا اَلسَّلاَمُ عَنِ اَلنَّبِيِّ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ حَدِيثٌ طَوِيلٌ وَ فِيهِ خُطْبَةُ اَلْغَدِيرِ وَ فِيهَا قَالَ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ بَعْدَ أَنْ ذَكَرَ عَلِيّاً وَ أَوْلاَدَهُ عَلَيْهِمُ اَلسَّلاَمُ: أَلاَ إِنَّ أَعْدَاءَهُمُ اَلَّذِينَ يَسْمَعُونَ لِجَهَنَّمَ شَهِيقاً وَ هِيَ تَفُورُ، وَ لَهَا زَفِيرٌ كُلَّمَا دَخَلَتْ أُمَّةٌ لَعَنَتْ أُخْتَهَا. (تفسير نور الثقلين : جُزْء ٥ صَفْحَة ٣٨١)

* នៅក្នុងសាត្រា អាល់-អ៊ុះហ្ស៊ាទីយ៉ាជ្ជ់ របស់ អាល់-ត្ប៊ារីសុ យោលតាមបណ្តាញព័ត៌មានលោកឡើងទៅដល់អ៊ីមុាំ មូហ្ហាំម៉ាដ្ជ់ ប៊ិន អ្ហាលី អាល់-បាក្ជ៊ៀរ តមកពីព្រះសាស្តា ﷺ នៅក្នុងហ្ជាឌ្ជីស្ជ្ជ៊ីងមួយ ។ នៅក្នុងហ្ជាឌ្ជីស្ជ្ជ៊ីងនេះមានឃ្ជ៊ុតបាស់ អាល់-ក៏ដ្ជ៊ៀរ ។ បន្ទាប់ពីបានថ្លែងរឿងអ្ហាលីនិងព្រះរាជបុត្រ ﷺ ព្រះអង្គ ﷺ នៅក្នុងឃ្ជ៊ុតបាស់នេះ ព្រះសាស្តា ﷺ មានព្រះវចន:ថា៖ "សត្រូវរបស់ពួកគេ ﷺ គឺពួកដែលនឹងឮនរក *[៦៧:៧] ដកដង្ហើម ។ ១ ។ ១ ។* នរកនោះដកដង្ហើមចេញ ។ រាល់ពេលដែលសហគមន៍ណាមួយចូលទៅក្នុងនរកនោះ សហគមន៍នោះនឹងជេរផ្តាសាដៃគូខ្លួន ។"
(تفسير نور الثقلين 5: 381)

وَقَالُواْ لَوۡ كُنَّا نَسۡمَعُ أَوۡ نَعۡقِلُ مَا كُنَّا فِيٓ أَصۡحَٰبِ ٱلسَّعِيرِ ١٠

១០. ពួកគេនឹងថា៖ "បើយើងបានស្តាប់ឬបានប្រើប្រាជ្ញា យើងច្បាស់ជានឹងមិនបាននៅក្នុងចំណោមជនភ្លើងនរកទេ ។"

فَٱعۡتَرَفُواْ بِذَنۢبِهِمۡ فَسُحۡقٗا لِّأَصۡحَٰبِ ٱلسَّعِيرِ ١١

១១. ដូច្នេះពួកគេនឹងទទួលស្គាល់បាបរបស់ខ្លួន ។ ការឃ្លាតឃ្លា[ពីការអត់ឱនទោស]បានលើពួកភ្លើងនរក ។"

អធិប្បាយអាយ៉ាស់ ១០-១១

علي بن إبراهيم: ''وَ قالُوا لَوْ كُنَّا نَسْمَعُ أَوْ نَعْقِلُ ما كُنَّا فِي أَصْحابِ السَّعِيرِ''، قال: قد سمعوا و عقلوا، و لكنهم لم يطيعوا و لم يفعلوا، و الدليل على أنهم قد سمعوا و عقلوا و لم يقبلوا، قوله: ''فَاعْتَرَفُوا بِذَنْبِهِمْ فَسُحْقاً لِأَصْحابِ السَّعِيرِ''.** (تفسير القمّيّ : جُزْء ٢ صَفْحَة ٣٧٨ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤١ حَدِيث: ٩٩/ ١٠٩١٤)

ទាក់ទងនឹងព្រះបន្ទូលអល់ឡោះហ្ស៊ីវ៉ាជ *[៦៧:១០] ពួកគេនឹងថា៖ "បើយើងបានស្តាប់ឬបានប្រើប្រាជ្ញា យើងច្បាស់ជានឹងមិនបាននៅក្នុងចំណោមជនភ្លើងនរកទេ ។"* អ៊ីម៉ាំ ﷺ មានវចន:ថា៖ "ពួកគេបានឮ និងបានគិត តែពួកគេមិនស្តាប់បង្គាប់និងមិនអនុវត្តតាមទេ ។ ភ័ស្តុតាងជាក់ស្តែងបញ្ជាក់ថាពួកគេបានឮហើយបានគិតតែមិនបានអនុវត្តតាមទេនោះ គឺព្រះបន្ទូលអល់ឡោះហ្ស៊ីវ៉ាជ *[៦៧:១១] ដូច្នេះពួកគេនឹងទទួលស្គាល់បាបរបស់ខ្លួន ។ ការឃ្លាតឃ្លាបានលើពួកភ្លើងនរក ។"* (تفسير القمّي 2: 378)

***

(كِتَابِ صِفَةِ الْجَنَّةِ وَ النَّارِ): عَنْ سَعِيدِ بْنِ جَنَاحٍ، قَالَ: حَدَّثَنِي عَوْفُ بْنُ عَبْدِ اللَّهِ الْأَزْدِيُّ، عَنْ جَابِرِ ابْنِ يَزِيدَ الْجُعْفِيِّ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ)، فِي حَدِيثٍ يَذْكُرُ فِيهِ أَهْلَ النَّارِ: «فَيَقُولُونَ: إِنْ عَذَّبَنَا رَبُّنَا، لَمْ يَكُنْ ظَلَمَنَا شَيْئاً- قَالَ- فَيَقُولُ مَالِكٌ: "فَاعْتَرَفُوا بِذَنْبِهِمْ فَسُحْقاً لِأَصْحَابِ السَّعِيرِ" أَيْ بُعْداً لِأَصْحَابِ السَّعِيرِ».** (الإختصاص : صَفْحَة ٣٦٤ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤١ حَدِيث: ٩٩/ ١٠٩١٥)

នៅក្នុងសាត្រា ស្ហ្ស៊ីហ្ហាស់ អាល់-យ៉ាន់ណាស់ រ៉ាន់-ណារ [...] អាប៊ូ យ៉ាកុ៉ាហ្ហារ ﷺ មានវចន:នៅក្នុងហ្ហាឌ៊ីស្ស មួយស្តីអំពីពួកភ្លើងនរកថា៖ "ពួកគេនឹងថា៖ "ព្រះម្ចាស់ ﷻ យើងធ្វើទោសយើង តែព្រះអង្គមិនប្រព្រឹត្តដោយអយុត្តិធម៌លើយើងក្នុងករណីណាមួយឡើយ ។" ម៉ាលិក ﷺ (ឆ្មាំនរក) នឹងថា៖ *"[៦៧:១១] ដូច្នេះពួកគេនឹងទទួលស្គាល់បាបរបស់ខ្លួន ។ ការឃ្លាតឃ្លាបានលើពួកភ្លើងនរក"* ពោលគឺ ដាច់ស្រយាល[ពីការបាននូវអារអភ័យទោស]សម្រាប់ជនភ្លើងនរក ។" (الاختصاص: 364)

إِنَّ ٱلَّذِينَ يَخۡشَوۡنَ رَبَّهُم بِٱلۡغَيۡبِ لَهُم مَّغۡفِرَةٞ وَأَجۡرٞ كَبِيرٞ ١٢

១២. បណ្តាអ្នកដែលខ្លាចព្រះម្ចាស់ខ្លួនក្នុងអាថិកំបាំង ជនទាំងនោះនឹងបានទទួលការអត់ឱនទោស និងរង្វាន់ធំ ។

وَأَسِرُّواْ قَوۡلَكُمۡ أَوِ ٱجۡهَرُواْ بِهِۦٓۖ إِنَّهُۥ عَلِيمُۢ بِذَاتِ ٱلصُّدُورِ ١٣

១៣. ទោះបីពួកអ្នកបិទបាំងសំដីពួកអ្នកឬបើកឲ្យដឹងឮក៏ដោយ ក៏ព្រះអង្គទ្រង់ញាណអ្វីដែលមាននៅក្នុងទ្រូង ។

أَلَا يَعۡلَمُ مَنۡ خَلَقَ وَهُوَ ٱللَّطِيفُ ٱلۡخَبِيرُ ١٤

១៤. ព្រះអ្នកបង្កើតមិនទ្រង់ញាណទេ ? ព្រះទ្រង់សុខុមបំផុត (ឈ្លាសវៃល្អិតល្អន់បំផុត) ព្រះអ្នកដឹងធ្ងុះធ្លាយ ។

អធិប្បាយអាយ៉ាស់ ១២-១៤

وَ عَنْهُ، قَالَ: حَدَّثَنَا مُحَمَّدُ بْنُ عَلِيٍّ مَاجِيلَوَيْهِ (رَحِمَهُ اللَّهُ)، قَالَ: حَدَّثَنَا عَلِيُّ بْنُ إِبْرَاهِيمَ بْنِ هَاشِمٍ، عَنِ الْمُخْتَارِ بْنِ مُحَمَّدِ بْنِ الْمُخْتَارِ الْهَمْدَانِيِّ، عَنِ الْفَتْحِ بْنِ يَزِيدَ الْجُرْجَانِيِّ، عَنْ أَبِي الْحَسَنِ (عَلَيْهِ السَّلاَمُ)- فِي حَدِيثٍ- قَالَ: فَقَوْلُكَ: ''اَللَّطِيفُ الْخَبِيرُ'' فَسِّرْهُ [لِي] كَمَا فَسَّرْتَ الْوَاحِدَ، فَإِنِّي أَعْلَمُ أَنَّ لُطْفَهُ عَلَى خِلاَفِ لُطْفِ خَلْقِهِ لِلْفَصْلِ، غَيْرَ أَنِّي أُحِبُّ أَنْ تَشْرَحَ لِي ذَلِكَ؟

អាល់-ហ្វាតាស៊ុ ប៊ិន យ៉ាស៊ីដ អាល់-យ៉ាហ្ជ៉ានីបានតំណាលថា នៅក្នុងហ្ជាឌ្ជីស្ស មួយ ខ្ញុំបានសួរ អាប៊ូ អាល់-ហ្ជាសាន់ صلوات الله عليه والسلام ថា៖ "ព្រះអង្គ صلوات الله عليه والسلام បានថា *[៦៧:១៤] ព្រះទ្រង់សុខុម ព្រះអ្នកដឹងធ្ងុះធ្លាយ ។* សូមព្រះអង្គ صلوات الله عليه والسلام ពន្យល់សម្តីនេះ ឲ្យទូលបង្គំបានជ្រាប ដូចដែលព្រះអង្គ صلوات الله عليه والسلام បានពន្យល់ "ព្រះមួយគត់" ផង ព្រោះទូលបង្គំចង់ដឹងជាលំអិតថាខុសគ្នាត្រង់ណាខ្លះរវាង ព្រះសុខុមភាព និង សុខុមភាពរបស់សត្វលោករបស់ព្រះអង្គ ﷻ នោះ ។ ទូលបង្គំចង់ឲ្យព្រះអង្គ صلوات الله عليه والسلام ពន្យល់ឲ្យទូលបង្គំណាស់ ?"

فَقَالَ: «يَا فَتْحُ، إِنَّمَا قُلْنَا اللَّطِيفُ، لِلْخَلْقِ اللَّطِيفِ، وَ لِعِلْمِهِ بِالشَّيْءِ اللَّطِيفِ، أَ وَ لاَ تَرَى- وَفَّقَكَ اللَّهُ وَ ثَبَّتَكَ- إِلَى أَثَرِ صُنْعِهِ فِي النَّبَاتِ اللَّطِيفِ وَ غَيْرِ اللَّطِيفِ وَ فِي [الْخَلْقِ اللَّطِيفِ] مِنَ الْحَيَوَانِ الصِّغَارِ مِنَ الْبَعُوضِ وَ الْجِرْجِسِ وَ مَا [هُوَ] أَصْغَرُ مِنْهُمَا مِمَّا لاَ تَكَادُ تَسْتَبِينُهُ الْعُيُونُ، بَلْ لاَ يَكَادُ يُسْتَبَانُ- لِصِغَرِهِ- اَلذَّكَرُ مِنَ الْأُنْثَى، وَ الْحَدَثُ الْمَوْلُودُ مِنَ الْقَدِيمِ،

ព្រះអង្គ صلوات الله عليه والسلام មានវចន:ថា៖ "ហ្វាតាស៊ុអើយ! យើងថា "សុខុម" គឺសម្រាប់សត្វលោករបស់ព្រះអង្គ ﷻ ដែលសុខុម (ល្អិតល្អន់) និងសម្រាប់ព្រះអភិញ្ញារបស់ព្រះអង្គ ﷻ អំពីភាពសុខុមរបស់សព្វសារពើ ។ ឬលោកមិនឃើញទេ - សូមអល់ឡោះហ្ជ៉ា ﷻ ជួយជ្រោមជ្រែងលោកនិងជួយឲ្យលោករឹងមាំ - លទ្ធផលនៃទង្វើរបស់អល់ឡោះហ្ជ៉ា ﷻ ដែលមាននៅក្នុងរុក្ខជាតិដែលទន់និងមិនសុខុម (គឺរឹង) និងក្នុងការបង្កើតដែលសុខុម (ដែលឈ្លាសវៃល្អិតល្អន់) នូវសត្វល្អិត ដូចជាសត្វរុយនិងសត្វមូសជាដើម និងអ្វីដែលតូចជាងទាំងពីរនេះទៀតដែលមិនអាចទាំងមើលឃើញបានដោយភ្នែកផងនោះ ។ តែមិនអាចដឹងបានទេថាមួយណាឈ្មោលមួយណាមេ (រវាងអម្បូរសត្វទាំងពីរនេះ) មិនដឹងថាមួយណាចាស់មួយណាក្មេងទេ ។

فَلَمَّا رَأَيْنَا صِغَرَ ذَلِكَ وَ لُطْفَهُ، وَ اهْتِدَاءَهُ لِلسِّفَادِ وَ الْهَرَبَ مِنَ الْمَوْتِ، وَ الْجَمْعَ لِمَا يُصْلِحُهُ مِمَّا فِي لُجَجِ الْبِحَارِ وَ مَا فِي لِحَاءِ الْأَشْجَارِ وَ الْمَفَاوِزِ وَ الْقِفَارِ، وَ فَهْمَ بَعْضِهَا عَنْ بَعْضٍ مَنْطِقَهَا، وَ مَا تَفْهَمُ بِهِ أَوْلاَدَهَا عَنْهَا، وَ نَقْلَهَا الْغِذَاءَ إِلَيْهَا، ثُمَّ تَأْلِيفَ أَلْوَانِهَا حُمْرَةٍ مَعَ صُفْرَةٍ وَ بَيَاضٍ مَعَ حُمْرَةٍ، وَ مَا لاَ تَكَادُ عُيُونُنَا تَسْتَبِينُهُ بِتَمَامِ خَلْقِهَا، وَ لاَ تَرَاهُ عُيُونُنَا، وَ لاَ تَمَسُّهُ أَيْدِينَا،عَلِمْنَا أَنَّ خَالِقَ هَذَا الْخَلْقِ لَطِيفٌ، لَطُفَ فِي خَلْقِ مَا سَمَّيْنَاهُ بِلاَ عِلاَجٍ وَ لاَ أَدَاةٍ وَ لاَ آلَةٍ، وَ أَنَّ كُلَّ صَانِعِ شَيْءٍ فَمِنْ شَيْءٍ صَنَعَ، وَ اللَّهُ الْخَالِقُ اللَّطِيفُ خَلَقَ وَ صَنَعَ لاَ مِنْ شَيْءٍ».** (التوحيد : صَفْحَة ١٨٦ حَدِيث ١ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤٢ حَدِيث: ٩٩/ ١٠٩١٨)

ដូច្នេះពេលយើងឃើញភាពតូចរបស់អ្វីៗទាំងនេះនិងសុខុមភាពរបស់ពួកវា ឃើញពួកវាចេញពីភាពពុករលួយ ឃើញពួកវាគេចពីសេចក្ដីស្លាប់ ឃើញការប្រមូលអ្វីៗដែលនៅឯបាតសមុទ្រ និងអ្វីៗដែលនៅលើមែកឈើ នៅឯទីរហោឋាននិងតំបន់ព្រៃភ្នំ យើងអាចយល់បានថាពួកវាមួយប្រភេទនិយាយរកគ្នា កូនពួកវាយល់ពួកវា និងដឹងថាពួកវាឲ្យចំណីកូនៗពួកវាដូចម្ដេចខ្លះ ។ បន្ទាប់មកយើងស្គាល់ព័ណ៌ពួកវាក្រហមជាមួយលឿង សជាមួយក្រហម ។ ភ្នែកយើងឃើញយ៉ាងពិបាកនូវការបង្កើតវាលុះចប់សព្វគ្រប់ ។ ភ្នែកយើងមើលមិនឃើញវាទេ ដៃយើងក៏មិនអាចប៉ះវាបានដែរ ។ យើងអាចដឹងបានថាព្រះអ្នកបង្កើតសត្វលោកនេះទ្រង់សុខុម (គឺឈ្លាសវៃល្អិតល្អន់ណាស់) ដោយបង្កើតវាឡើងដោយគ្មានគ្រឿងឧបករណ៍ឬគ្រឿងចក្រណាមួយឡើយ ។ សព្វសារពើដែលត្រូវបង្កើតមក ព្រះមួយគត់ជាអ្នកបង្កើតវា អល់ឡោះហ្គ៌ីﷻជាព្រះអ្នកបង្កើត គឺព្រះទ្រង់សុខុមដែលបង្កើតនិងធ្វើឲ្យ[អ្វីៗ]កើតមកពីភាពទទេគ្មានអ្វីសោះ ។" (التوحيد: 1 /186)

***

ابْنُ بَابَوَيْهِ، قَالَ: حَدَّثَنَا عَلِيُّ بْنُ أَحْمَدَ بْنِ مُحَمَّدِ بْنِ عِمْرَانَ الدَّقَّاقُ (رَحِمَهُ اللَّهُ)، قَالَ: حَدَّثَنَا مُحَمَّدُ ابْنُ يَعْقُوبَ الْكُلَيْنِيُّ، قَالَ: حَدَّثَنَا عَلِيُّ بْنُ مُحَمَّدٍ، عَنْ مُحَمَّدِ بْنِ عِيسَى، عَنِ الْحُسَيْنِ بْنِ خَالِدٍ، عَنْ أَبِي الْحَسَنِ الرِّضَا (عَلَيْهِ السَّلاَمُ)، قَالَ: «إِنَّمَا سُمِّيَ اللَّهُ بِالْعِلْمِ لِغَيْرِ عِلْمٍ حَادِثٍ عَلِمَ بِهِ الْأَشْيَاءَ، وَ اسْتَعَانَ بِهِ عَلَى حِفْظِ مَا يَسْتَقْبِلُ مِنْ أَمْرِهِ، وَ الرِّوَيَةِ فِيمَا يَخْلُقُ [مِنْ خَلْقِهِ] وَ بِعَيْنِهِ مَا مَضَى مِمَّا أَفْنَى مِنْ خَلْقِهِ مِمَّا لَوْ لَمْ يَحْضُرْهُ ذَلِكَ الْعِلْمُ وَ يَعْنِهِ كَانَ جَاهِلاً ضَعِيفاً، كَمَا أَنَّا رَأَيْنَا عُلَمَاءَ الْخَلْقِ إِنَّمَا سُمُّوا بِالْعِلْمِ لِعِلْمٍ حَادِثٍ إِذْ كَانُوا قَبْلَهُ جَهَلَةً، وَ رُبَّمَا فَارَقَهُمُ الْعِلْمُ بِالْأَشْيَاءِ، فَصَارُوا إِلَى الْجَهْلِ، وَ إِنَّمَا سُمِّيَ اللَّهُ عَالِماً لِأَنَّهُ لاَ يَجْهَلُ شَيْئاً، وَ قَدْ جَمَعَ الْخَالِقَ وَ الْمَخْلُوقَ [اسْمُ الْعِلْمِ] وَ اخْتَلَفَ الْمَعْنَى عَلَى مَا رَأَيْتَ.** (التوحيد : صَفْحَة ١٨٨ حَدِيث ٢ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤١ حَدِيث: ١٠٩١٧ /٩٩)

[...] អាល់-ហ្ជ្រ៉ាសែន ប៊ិន ខ្ជ៉ាលិដ្ជបានតំណាលថា អាប៊ូ អាល់-ហ្ជាសាន់ អាល់-រ៉ីដ្ជ៉ីﷺមានវចន:ថា: "យើងថា "អល់ឡោះហ្គ៌ីﷻទ្រង់ញាណ" នេះមិនមែនព្រះអភិញ្ញាក្រោយពីព្រះអង្គﷻបានបង្កើតសព្វសារពើនោះទេ ។ ព្រះអង្គﷻប្រើព្រះអភិញ្ញានេះសម្រាប់រក្សាការពារនូវអ្វីដែលនឹងកើតឡើងតាមព្រះបញ្ជាព្រះអង្គﷻ សម្រាប់ធ្វើសេចក្ដីរាយការណ៍អំពីសត្វលោកដែលព្រះអង្គﷻបានបង្កើតមកនិងដែលបានស្លាប់ទៅហើយ ។ ព្រះអ្នកបង្កើតវា បើព្រះអង្គﷻមិនមានព្រះអភិញ្ញានោះទេ បានសេចក្ដីថាគ្មានការចេះដឹងនិងអន់ខ្សោយ ប្រៀបបាននឹងជនមានចំណេះក្នុងចំណោមសត្វលោកទាំងឡាយដែលគេហៅថាអ្នកប្រាជ្ញនោះ ព្រោះពួកគេទាំងនោះបានមកនូវការចេះដឹង ព្រោះកាលពីមុនពួកគេអវិជ្ជា (មិនចេះដឹងទេ) ការចេះដឹងអំពីអ្វីៗទាំងនេះនឹងត្រូវបែកពីពួកគេ ដូច្នេះពួកគេនឹងក្លាយទៅជាជនអវិជ្ជាម្ដងទៀតនៅទីបំផុត ។ គេហៅអល់ឡោះហ្គ៌ីﷻថាព្រះទ្រង់ញាណពីព្រោះព្រះអង្គﷻមិនលង់ខ្លៅ មិនអវិជ្ជាអំពីអ្វីមួយឡើយ ។ ដូច្នេះគេហៅព្រះអ្នកបង្កើតនិងអ្វីដែលត្រូវបង្កើតមកថាអ្នកបង្កើត ការពិតវាមានន័យខុសគ្នា ដូចដែលលោកបានដឹងស្រាប់ហើយ ។" (التوحيد: 2 /188)

هُوَ ٱلَّذِى جَعَلَ لَكُمُ ٱلْأَرْضَ ذَلُولًا فَٱمْشُوا۟ فِى مَنَاكِبِهَا وَكُلُوا۟ مِن رِّزْقِهِۦ ۖ وَإِلَيْهِ ٱلنُّشُورُ ﴿١٥﴾

១៥. ព្រះអង្គជាអ្នកធ្វើឲ្យដែនដីរាបស្មើសម្រាប់ពួកអ្នក ។ ដូច្នេះចូរពួកអ្នកចរគ្រាច់លើផ្ទៃដីដ៏ធំទូលាយនោះ ចូរពួកអ្នកបរិភោគនូវគ្រឿងទ្រទ្រង់ជីវិតរបស់ព្រះអង្គ ។ ការរស់ពីស្លាប់វិញគឺឆ្ពោះទៅឯព្រះអង្គ ។

ءَأَمِنتُم مَّن فِى ٱلسَّمَآءِ أَن يَخۡسِفَ بِكُمُ ٱلۡأَرۡضَ فَإِذَا هِىَ تَمُورُ ١٦

១៦. ពួកអ្នកជឿជាក់ថាមានសុវត្ថិភាពឬ ថាព្រះដែល[ទ្រង់រាជ្យ]នៅលើមេយនឹងមិនពង្លិចពួកអ្នកទៅក្នុងដីទេ [ដោយសារអំពើអាក្រក់ដែលពួកអ្នកបានសាងនោះ] នៅពេលវារញ្ជួយ ?

أَمۡ أَمِنتُم مَّن فِى ٱلسَّمَآءِ أَن يُرۡسِلَ عَلَيۡكُمۡ حَاصِبٗاۖ فَسَتَعۡلَمُونَ كَيۡفَ نَذِيرِ ١٧

១៧. ឬពួកអ្នកជឿជាក់ថាមានសុវត្ថិភាពឬ ថាព្រះដែល[ទ្រង់រាជ្យ]នៅលើមេយនឹងមិនបញ្ជូនមកលើពួកអ្នកនូវព្យុះដុំថ្មទេ[ដោយសារពួកអ្នកសាងអំពើអាក្រក់] ? ដូច្នេះពួកអ្នកនឹងបានដឹងថាការដាស់តឿនរបស់អញនោះដូចម្តេចខ្លះ ។

وَلَقَدۡ كَذَّبَ ٱلَّذِينَ مِن قَبۡلِهِمۡ فَكَيۡفَ كَانَ نَكِيرِ ١٨

១៨. ពិតណាស់ ជនមុនពួកគេ (ពួកបដិសេធសទ្ធា ពួកគោរពបូជារូបបដិមា ពួកលាក់ពុត ពួកពហុទេពនិយម ពួកទុច្ចរិត...) បានបដិសេធ[ព្រះសញ្ញា ព្រះឱង្ការ]រួចហើយ ។ ការច្រានចោលរបស់អញនោះដូចម្តេចខ្លះ ។

أَوَ لَمۡ يَرَوۡاْ إِلَى ٱلطَّيۡرِ فَوۡقَهُمۡ صَٰٓفَّٰتٖ وَيَقۡبِضۡنَۚ مَا يُمۡسِكُهُنَّ إِلَّا ٱلرَّحۡمَٰنُۚ إِنَّهُۥ بِكُلِّ شَىۡءِۭ بَصِيرٌ ١٩

១៩. ពួកគេមិនឃើញសត្វស្លាបនៅពីលើពួកគេទេ ដែលត្រដាងនិងបត់ស្លាប ? មានតែ [អល់ឡោះហ្ស៍] ព្រះដ៏មានព្រះមេត្តាធម៌ទេជាអ្នកទ្រពួកវា ។ ការពិត ព្រះអង្គទ្រង់ទស្សនាការសព្វសារពើ ។

أَمَّنۡ هَٰذَا ٱلَّذِى هُوَ جُندٞ لَّكُمۡ يَنصُرُكُم مِّن دُونِ ٱلرَّحۡمَٰنِۚ إِنِ ٱلۡكَٰفِرُونَ إِلَّا فِى غُرُورٍ ٢٠

២០. អ្នកណាដែលអាចជាទ័ពរបស់ពួកអ្នកដើម្បីជួយពួកអ្នក ក្រៅពី[អល់ឡោះហ្ស៍]ព្រះដ៏មានព្រះមេត្តាធម៌ ? ពួកបដិសេធសទ្ធា (ពួកគោរពបូជារូបបដិមា ពួកលាក់ពុត ពួកធ្វើផែនការឧក្រិដ្ឋ...) មិនស្ថិតនៅក្នុងអ្វីក្រៅពីការបញ្ឆោតទេ ។

أَمَّنۡ هَٰذَا ٱلَّذِى يَرۡزُقُكُمۡ إِنۡ أَمۡسَكَ رِزۡقَهُۥۚ بَل لَّجُّواْ فِى عُتُوّٖ وَنُفُورٍ ٢١

២១. អ្នកណានឹងផ្តល់ភក្សាហារឲ្យពួកអ្នក បើព្រះអង្គផ្អាកភក្សាហាររបស់ព្រះអង្គ ? តែពួកគេចចេសប្រមាថនិងស្អប់ខ្ពើម ។

អធិប្បាយអាយ៉ាស់ ១៥-២១

علي بن إبراهيم، قوله: ''هُوَ الَّذِي جَعَلَ لَكُمُ الْأَرْضَ ذَلُولًا'' أي فراشا ''فَامْشُوا فِي مَناكِبِها'' أي في أطرافها.** (تفسير القمّيّ : جُزْء ٢ صَفْحَة ٣٧٩ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤٣ حَدِيث: ٩٩/ ١٠٩١٩)

អ្ហាលី បិន អ៊ីបរ៉ហ្ស៊ីម [នៅក្នុងតាហ្ស៉សៀរគ្ឌុម៉ី] បានថ្លែងអំពីព្រះបន្ទូលអល់ឡោះហ្ស៍ ﷻ [៦៧:១៥] ព្រះអង្គ

ជាអ្នកធ្វើឲ្យផែនដីរាបស្មើសម្រាប់ពួកអ្នក ពោលគឺ ដូចពួក *ដូច្នេះចូរពួកអ្នកចរគ្រាច់លើផ្ទៃដីដ៏ធំទូលាយនោះ* ពោលគឺ ទៅឯគែមវា ។

***

* و قال: {أَ أَمِنْتُمْ مَنْ فِي السَّمَاءِ أَنْ يَخْسِفَ بِكُمُ الْأَرْضَ فَإِذَا هِيَ تَمُورُ * أم أمنتم من في السماء أن يرسل عليكم حاصباً فستعلمون كيف نذير}. وَ قَالَ أَمِيرُ الْمُؤْمِنِينَ عَلَيْهِ السَّلاَمُ : كَانَ فِي اَلنَّاسِ أَمَانَانِ رَسُولُ اَللَّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ وَ اَلاِسْتِغْفَارُ فَرُفِعَ مِنْهُمْ أَمَانٌ وَ هُوَ رَسُولُ اَللَّهِ وَ بَقِيَ عَلَيْهِمْ أَمَانٌ وَ هُوَ اَلاِسْتِغْفَارُ .

* [នៅក្នុងសាត្រា អៀវស្នាជុំ អាល់-គូលូប របស់ អាល់-ដៃឡាមី] អល់ឡោះហ៊្វ៍تعالىមានព្រះបន្ទូលថា៖ *[៦៧:១៦] ពួកអ្នកជឿជាក់ថាមានសុវត្ថិភាពឬ ថាព្រះដែលនៅលើមេឃនឹងមិនពង្លិចពួកអ្នកទៅក្នុងដីទេ នៅពេលវារញ្ជួយ ? [៦៧:១៧] ឬពួកអ្នកជឿជាក់ថាមានសុវត្ថិភាពឬ ថាព្រះដែលនៅលើមេឃនឹងមិនបញ្ជូនមកលើពួកអ្នកនូវព្យុះដុំថ្មទេ[ដោយសារពួកអ្នកសាងអំពើអាក្រក់] ? ដូច្នេះពួកអ្នកនឹងបានដឹងថាការដាស់តឿនរបស់អញនោះដូចម្តេចខ្លះ ។* អាមីរុល-មុមីនីនصلوات الله عليه والسلامមានវចនៈថា៖ "មានសុវត្ថិភាពពីរ ទាក់ទងនឹងមនុស្សគឺ [វត្តមានរបស់]រ៉ស៊ូលុលឡោះហ៊្វ៍ﷺនិងការសូមខមាទោស ។ បន្ទាប់មក សុវត្ថិភាពមួយត្រូវលើកចេញពីពួកគេ នោះគឺរ៉ស៊ូលុលឡោះហ៊្វ៍ﷺ នៅសល់សុវត្ថិភាពមួយលើពួកគេនោះគឺការសូមខមាទោស ។

وَ قَالَ رَسُولُ اَللَّهِ صَلَّى اَللَّهُ عَلَيْهِ وَ آلِهِ: وَ لَوْ أَنَّهُمْ حِينَ تَنْزِلُ عَنْهُمُ اَلنِّعَمُ وَ تَحُلُّ بِهِمُ اَلنِّقَمُ فَزِعُوا إِلَى اَللَّهِ تَوْبَةً بِوَلَهٍ مِنْ نُفُوسِهِمْ وَ صِدْقٍ مِنْ نِيَّاتِهِمْ وَ خَالِصٍ مِنْ طَوِيَّاتِهِمْ لَرَدَّ عَلَيْهِمْ كُلَّ شَارِدٍ وَ لَأَصْلَحَ لَهُمْ كُلَّ فَاسِدٍ.

រ៉ស៊ូលុលឡោះហ៊្វ៍ﷺមានព្រះវចនៈថា៖ "ពេលដែលព្រះឧបការគុណអន់ថយ ពួកគេមានទុក្ខ បើពួកគេសារទុក្ខភ័យប្រាប់អល់ឡោះហ៊្វ៍ﷻ ដោយសូមស្មារលាកំហុសរបស់ខ្លួន ដោយស្មោះអស់ពីចិត្ត ដោយសារភាពខ្លួនដោយស្មោះ គ្រប់វត្ថុដែលបានរបូតរួចទៅបាត់ហើយនោះនឹងវិលត្រឡប់មករកពួកគេវិញ គ្រប់ប្រការដែលបានខូចទៅហើយនោះនឹងត្រូវកែតម្រូវឲ្យពួកគេវិញ ។"

وَ قَالَ اَلنَّبِيُّ: إِنَّ اَللَّهَ تَعَالَى خَلَقَ مَلَكاً يَنْزِلُ فِي كُلِّ لَيْلَةٍ يُنَادِي يَا أَبْنَاءَ اَلْعِشْرِينَ جِدُّوا وَ اِجْتَهِدُوا وَ يَا أَبْنَاءَ اَلثَّلاَثِينَ لاَ تَغُرَّنَّكُمُ اَلْحَيَاةُ اَلدُّنْيَا وَ يَا أَبْنَاءَ اَلْأَرْبَعِينَ مَا ذَا أَعْدَدْتُمْ لِلِقَاءِ رَبِّكُمْ

ព្រះសាស្តាﷺមានព្រះវចនៈថា៖ "អល់ឡោះហ៊្វ៍تعالىបានបង្កើតទេវតាមួយដែលចុះមកប្រកាសរាល់យប់ថា៖ "បណ្តាអ្នកវ័យម្ភៃឆ្នាំអើយ ចូរតស៊ូ ចូរខំពុះពារ ។" "បណ្តាអ្នកវ័យសាមសិបឆ្នាំអើយ ចូរកុំបណ្តោយឲ្យជីវិតលោកនេះបញ្ឆោតអស់លោកបានឡើយ ។" បណ្តាអ្នកវ័យសែសិបឆ្នាំអើយ តើអស់លោកបានត្រៀមទុកអ្វីខ្លះហើយសម្រាប់ជួបព្រះម្ចាស់ﷻរបស់អស់លោក ?"

وَ يَا أَبْنَاءَ اَلْخَمْسِينَ أَتَاكُمُ اَلنَّذِيرُ وَ يَا أَبْنَاءَ اَلسِّتِّينَ زَرْعٌ آنَ حَصَادُهُ وَ يَا أَبْنَاءَ اَلسَّبْعِينَ نُودِيَ لَكُمْ فَأَجِيبُوا وَ يَا أَبْنَاءَ اَلثَّمَانِينَ أَتَتْكُمُ اَلسَّاعَةُ وَ أَنْتُمْ غَافِلُونَ

"បណ្តាអ្នកវ័យហាសិបឆ្នាំអើយ អ្នកព្រមានបានមករកអស់លោកហើយ ។" "បណ្តាអ្នកវ័យហុកសិបឆ្នាំ

អឺយ ចូរអស់លោកដាំ (សាប, ព្រោះ...) ដើម្បីអស់លោកនឹងអាចប្រមូលផលបាន ។" បណ្តាអ្នកវ័យចិតសិបឆ្នាំអឺយ គេបានប្រកាសហៅអស់លោកហើយ ដូច្នេះចូរអស់លោកឆ្លើយតប ។" បណ្តាអ្នកវ័យប៉ែតសិបឆ្នាំអឺយ ពេលវេលាបានមកដល់អស់លោកហើយ អស់លោក[នៅតែ]ធ្វេសប្រហែស ។"

ثُمَّ يَقُولُ لَوْ لاَ عِبَادٌ رُكَّعٌ وَ رِجَالٌ خُشَّعٌ وَ صِبْيَانٌ رُضَّعٌ وَ أَنْعَامٌ رُتَّعٌ لَصُبَّ عَلَيْكُمُ الْعَذَابُ صَبّاً. (إرشاد القلوب إلى الصواب (للديلمي)، : جُزْء ١ صَفْحَة ٣١)

បន្ទាប់មកទេវតាថា៖ "ប្រសិនបើបាវមិនបង្អោនខ្លួនទេ (មិនរូគុអ៉ុទេ) បុរសមិនដាក់ខ្លួនទេ មិនមានទារកបៅដោះនិងដេកយ៉ាងសុខសាន្តទេ ព្រះទណ្ឌកម្មច្បាស់ជាហូរស្រោចមកលើអស់លោក ។"
(إرشاد القلوب إلى الصواب (للديلمي) 1: 31)

أَفَمَن يَمْشِى مُكِبًّا عَلَىٰ وَجْهِهِۦٓ أَهْدَىٰٓ أَمَّن يَمْشِى سَوِيًّا عَلَىٰ صِرَٰطٍ مُّسْتَقِيمٍ ﴿٢٢﴾

២២. តើបុគ្គលដែលដើរសំយុងមុខ [ទៅរកដី ទៅរកបទប្រមាថសាសនា ។ ល ។] នោះបានទទួលការដឹកនាំប្រសើរជាងគេ ឬបុគ្គលដែលដើរត្រង់ខ្លួនលើមាគ៉ាត្រង់ត្រូវ ?

អធិប្បាយអាយ៉ាស់ ២២

مُحَمَّدُ بْنُ يَعْقُوبَ: عَنْ عَلِيِّ بْنِ مُحَمَّدٍ، عَنْ بَعْضِ أَصْحَابِنَا، عَنِ ابْنِ مَحْبُوبٍ، عَنْ مُحَمَّدِ بْنِ الْفُضَيْلِ، عَنْ أَبِي الْحَسَنِ الْمَاضِي (عَلَيْهِ السَّلاَمُ)، قَالَ: قُلْتُ: ''أَ فَمَنْ يَمْشِي مُكِبًّا عَلىٰ وَجْهِهِ أَهْدىٰ أَمَّنْ يَمْشِي سَوِيًّا عَلىٰ صِرٰاطٍ مُسْتَقِيمٍ''؟ قَالَ: «إِنَّ اللَّهَ ضَرَبَ مَثَلاً مَنْ حَادَ عَنْ وَلاَيَةِ عَلِيٍّ (عَلَيْهِ السَّلاَمُ) كَمَنْ يَمْشِي عَلَى وَجْهِهِ، لاَ يَهْتَدِي لِأَمْرِهِ، وَ جَعَلَ مَنْ تَبِعَهُ سَوِيّاً عَلَى صِرَاطٍ مُسْتَقِيمٍ، وَ الصِّرَاطُ الْمُسْتَقِيمُ أَمِيرُ الْمُؤْمِنِينَ (عَلَيْهِ السَّلاَمُ)».** (الكافي : جُزْء ١ صَفْحَة ٣٥٩ حَدِيث ٩١ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤٣ حَدِيث: ٩٩/ ١٠٩٢٠)

អាប្វូ អាល់-ហ្ជាសាន់ صلوات الله عليه والسلام មានវចនៈថា៖ "*[៦៧:២២] តើបុគ្គលដែលដើរសំយុងនោះបានទទួលការដឹកនាំប្រសើរជាងគេ ឬបុគ្គលដែលដើរត្រង់ខ្លួនលើមាគ៉ាត្រង់ត្រូវ ?* អល់ឡោះហ្ជ៍ عز وجل បានលើកឧទាហរណ៍ថាមនុស្សដែលឃ្លាតឆ្ងាយពីវីឡាយ៉ាស់របស់អ្ជាលី صلوات الله عليه والسلام ដូចមនុសដែលដើរលើមុខខ្លួនងង មិនបានទទួលការដឹកនាំរឿងផ្ទាល់ខ្លួនរបស់អ្នកនោះទេ ។ អល់ឡោះហ្ជ៍ عز وجل ធ្វើឲ្យបុគ្គលដែលតាមព្រះអង្គ صلوات الله عليه والسلام ទៅជាបុគ្គលដែលស្ថិតនៅលើមាគ៉ាត្រង់ត្រូវ ។ *[៦៧:២២] មាគ៉ាត្រង់ត្រូវ* គឺអាមីរុល-មុមីនីន صلوات الله عليه والسلام ។"
(الكافي 1: 359/ 91)

***

مُحَمَّدُ بْنُ الْعَبَّاسِ: عَنْ حُمَيْدِ بْنِ زِيَادٍ، عَنِ الْحَسَنِ بْنِ مُحَمَّدِ بْنِ سَمَاعَةَ، عَنْ صَالِحِ بْنِ خَالِدٍ، عَنْ مَنْصُورٍ، عَنْ حَرِيزٍ، عَنْ فُضَيْلِ بْنِ يَسَارٍ، عَنْ أَبِي جَعْفَرٍ (عَلَيْهِ السَّلاَمُ)، قَالَ: تَلاَ هَذِهِ الْآيَةَ وَ هُوَ يَنْظُرُ إِلَى النَّاسِ ''أَ فَمَنْ يَمْشِي مُكِبًّا عَلىٰ وَجْهِهِ أَهْدىٰ أَمَّنْ يَمْشِي سَوِيًّا عَلىٰ صِرٰاطٍ مُسْتَقِيمٍ'':«يَعْنِي وَ اللَّهِ عَلِيّاً وَ الْأَئِمَّةَ (عَلَيْهِمُ السَّلاَمُ)».** (تأويل الآيات : جُزْء ٢ صَفْحَة ٧٠٢ حَدِيث ٢ ، البرهان في تفسير القرآن: جُزْء: ٥ صَفْحَة: ٤٤٣ حَدِيث: ٩٩/ ١٠٩٢١)

